## ស្ថានទូតអូស្ត្រាលី
## ប្រចាំព្រះរាជាណាចក្រកម្ពុជា

### សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២៣

# ដំណើរទស្សនកិច្ចរបស់បេសកជនពិសេសរបស់អូស្ត្រាលីប្រចាំតំបន់អាស៊ីអាគ្នេយ៍ មកកាន់ប្រទេសកម្ពុជា

សប្តាហ៍ក្រោយនេះ លោក Nicholas Moore ប្រេសិតពិសេសរបស់អូស្ត្រាលីប្រចាំតំបន់អាស៊ីអាគ្នេយ៍ នឹងមកបំពេញទស្សនកិច្ចនៅទីក្រុងភ្នំពេញ។ ទស្សនកិច្ចនេះជាផ្នែកមួយនៃដំណើរកិច្ចពិគ្រោះយោបល់ថ្នាក់តំបន់របស់លោក ដើម្បីជួយគាំទ្រដល់ការអភិវឌ្ឍយុទ្ធសាស្ត្រសេដ្ឋកិច្ចអាស៊ីអាគ្នេយ៍របស់រដ្ឋាភិបាលអូស្ត្រាលី ដល់ឆ្នាំ ២០៤០។

យុទ្ធសាស្ត្រនេះនឹងកំណត់មាគ៌ាជាក់ស្តែង ដើម្បីពង្រឹងការចូលរួមផ្នែកសេដ្ឋកិច្ចរបស់អូស្ត្រាលីជាមួយអាស៊ីអាគ្នេយ៍ ដោយគូសវាសឱកាសថ្មីៗ ដើម្បីជំរុញពាណិជ្ជកម្ម និងការវិនិយោគទ្វេភាគី។

ឯកឧត្តម Anthony Albanese នាយករដ្ឋមន្ត្រីអូស្ត្រាលី បានប្រកាសតែងតាំង លោក Nicholas Moore ជាប្រេសិតពិសេសប្រចាំទីក្រុងភ្នំពេញ កាលពីខែវិច្ឆិកាឆ្នាំកន្លងទៅ នៅពេលដែលឯកឧត្តមអញ្ជើញមកកាន់ប្រទេសកម្ពុជា ដើម្បីចូលរួមក្នុងកិច្ចប្រជុំកំពូលអាស៊ាន-អូស្ត្រាលីប្រចាំឆ្នាំលើកទី២ និងកិច្ចប្រជុំកំពូលអាស៊ីបូព៌ាលើកទី១៧។

លោក Nicholas Moore បានមានប្រសាសន៍ថា "ខ្ញុំរង់ចាំស្តាប់អំពីទស្សនៈវិស័យរបស់អ្នកដែលកំពុងរស់នៅក្នុងទីក្រុងភ្នំពេញ អំពីរបៀបដែលអូស្ត្រាលីអាចជួយបំពេញតម្រូវការសេដ្ឋកិច្ចដែលកំពុងរីកចម្រើនរបស់កម្ពុជា។"

"អូស្ត្រាលីមានអ្វីៗជាច្រើនដើម្បីផ្តល់ដល់ប្រទេសកម្ពុជា និងតំបន់ទាំងមូល ក្នុងនាមជាដៃគូដែលគួរឲ្យជឿជាក់ និងអាចទុកចិត្តបាន។"

នៅក្នុងដំណើរទស្សនកិច្ចមកកាន់ប្រទេសកម្ពុជា លោក Nicholas Moore ប្រេសិតពិសេស នឹងជួបជាមួយអ្នកជំនួញធំៗ មកពីវិស័យផ្សេងៗ រួមមាន កសិកម្ម អប់រំ រ៉ែ/ធនធាន និងធនាគារ។

ជាផ្នែកមួយនៃដំណើរទស្សនកិច្ចរបស់លោក លោក Nicholas Moore ក៏នឹងចូលរួមជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដាក់ឱ្យដំណើរការជាផ្លូវការនូវ "សៀវភៅស្តីពីការវិនិយោគនៅកម្ពុជា" ដែលជាការណែនាំជាក់ស្តែងសម្រាប់អ្នកវិនិយោគអូស្ត្រាលី និងបរទេសផ្សេងៗទៀត ដែលកំពុងស្វែងរកឱកាសនៅក្នុងទីផ្សារកម្ពុជា ដោយផ្តោតជាពិសេសលើច្បាប់ស្តីពីការវិនិយោគឆ្នាំ២០២១ (LOI)។

**ទំនាក់ទំនងព័ត៌មាន៖** Media.Cambodia@dfat.gov.au